គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY
CFC-CBC 23102020 K

# សេចក្តីថ្លែងការណ៍

## កម្ពុជា ៖ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ១៩៩១ ទល់និង សន្ធិសញ្ញាយួន ១៩៧៩ និង ហ៊ុន សែន

កិច្ចព្រមព្រៀងអន្តរជាតិ ទីក្រុងប៉ារីស ស្តីពីកម្ពុជា ឆ្នាំ១៩៩១ ជាកិច្ចព្រមព្រៀងភូមិសាស្ត្រនយោបាយ ដើម្បីសន្តិភាពនិងស្ថិរភាព នៅកម្ពុជាផង នៅតំបន់អាស៊ីអគ្នេយ៍ និងក្នុងពិភពលោកផង បន្ទាប់ពីមានសង្គ្រាមដ៏យោរយៅនៅយៀកណាម។ កិច្ចព្រមព្រៀងអន្តរជាតិនេះ បានអះអាងជាថ្មីនូវឯករាជ្យ និងអព្យាក្រឹត្យរបស់ប្រទេសកម្ពុជា ដែលមិនត្រូវរដ្ឋណា រំលោភឡើយ និងបានកំណត់លក្ខន្តិកៈផ្ទៃក្នុងថ្មីមួយ សម្រាប់រដ្ឋកម្ពុជា ដើម្បីការជានាជាតិ និងការកសាងឯកភាពជាតិ ដោយហាមមិនឲ្យរបបនយោបាយផ្តាច់ការ នៃអតីតកាល វិលត្រឡប់មកវិញ។ នេះជាកិច្ចសន្យាពិសេស រវាងហត្ថលេខីទាំងអស់ថា កម្ពុជាត្រូវបានអន្តរជាតិការពារ និងជួយជ្រោមជ្រែង ប៉ុន្តែត្រូវស្ថិតនៅក្រោមការឃ្លាំមើលជានិច្ចនៃអន្តរជាតិ ក្នុងការប្រព្រឹត្តនយោបាយអន្តរជាតិ និងនយោបាយផ្ទៃក្នុងរបស់ខ្លួន។ នៅក្នុងលក្ខខណ្ឌនេះ កម្ពុជាមិនមានអធិបតេយ្យ ១០០ភាគរយ ដូចរដ្ឋឯទៀតៗនោះទេ។

គេបានយកប្រទេសកម្ពុជា ជាចំណុចកណ្តាលនៃកិច្ចព្រមព្រៀងភូមិសាស្ត្រនយោបាយនេះ ពីព្រោះស្ថានភាពកម្ពុជាក្នុងទសវត្សរ៍ ១៩៧០-១៩៨០ វាបានកើតមក ពីសង្គ្រាមយៀកណាមនោះ។ យួនកុម្មុយនីស្ត៍ ដែលមានជ័យជំនះ លើបារាំង និងលើអាមេរិក និងបានកាន់កាប់យៀកណាមខាងត្បូង ហើយបានបន្តវាយប្រហារដើម្បីត្រួតត្រា លើអតីតឥណ្ឌូចិនបារាំង ហើយបម្រុងនឹងរុលទៅប្រទេសថៃ និង ម៉ាឡេស៊ី ផង។ យៀកណាមនេះ ត្រូវបានអន្តរជាតិ និងអង្គការសហប្រជាជាតិ(អ.ស.ប.) បរិហារ និងថ្កោលទោសជាខ្លាំង តាំងពីថ្ងៃដំបូងនៃសង្គ្រាមឈ្លានពាន ចូលកាន់កាប់កម្ពុជា។ ប៉ុន្តែនៅឆ្នាំ ១៩៨៧ យួនហាណូយ ដោយបានយល់ថា គេមិនអាចបន្តសង្គ្រាមកម្ពុជាយូរទៅទៀត ត្បិតប្រទេសកុម្មុយនីស្ត៍ នៃអឺរ៉ុបខាងកើត កំពុងរង្គោះរង្គើជាខ្លាំង និងមិនអាចផ្តល់ជំនួយឲ្យគេ សម្រាប់បន្តសង្គ្រាមនេះទេ។ គេបានប្តូរយុទ្ធសាស្ត្រ រកការចរចា «សន្តិភាព»វិញ ដោយបើកទំនាក់ទំនងជាថ្មី ជាមួយសម្តេច នរោត្តម សីហនុ និងរិះរកការចូលរួម ការចរចានៃអន្តរជាតិផង។ ពេលនោះ រដ្ឋាភិបាលបារាំង បានជួយសម្រួលជាច្រើន ដល់ផែនការ របស់យួនហាណូយ។

ការចម្លែកមួយដែលយើងបានឃើញ គឺកិច្ចព្រមព្រៀងសន្តិភាពអន្តរជាតិទីក្រុងប៉ារីសនោះ មិនបានលើកឈ្មោះប្រទេសយៀកណាម មកនិយាយមួយម៉ាត់ ដែលយៀកណាមនេះ ត្រូវបានថ្កោលទោសយ៉ាងច្បាស់លាស់ ជារៀងរាល់ឆ្នាំ ដោយ អ.ស.ប. តាំងពីឆ្នាំ១៩៨០ ចំពោះការឈ្លានពាន និងការកាន់កាប់ប្រទេសកម្ពុជា ដោយកងទ័ពដ៏មានឥទ្ធិពលរបស់ខ្លួន និងការបញ្ចូលជនជាតិយួន រាប់លាននាក់ មកធ្វើអាណានិគម

លើទឹកដីខ្មែរ។ ជាងនេះទៅទៀត ការវាយប្រហាររបស់យួន បានបន្តជាង ១០ឆ្នាំ ដោយបានបណ្ដាល ឱ្យស្លាប់ជនស៊ីវិលខ្មែរ ជាច្រើនសែននាក់ និងកម្ពុជា រងការខូចខាតឥតគណនា។

ជាបន្ទាប់មក ដោយសារការធ្វេសប្រហែស ឬការលម្អៀងទៅខាងយួន និង **ហ៊ុន សែន** នៃអ្នកការទូតជប៉ុន **យ៉ាស៊ូស៊ី អាកាស៊ី** (Yasushi Akashi) ដែលដឹកនាំអង្គការ អ៊ុនតាក់ (UNTAC) ក្នុងសម័យអន្តរកាល ការបណ្ដេញកងទ័ពបរទេស (យួន) ឲ្យអស់ពីកម្ពុជា ក៏មិនបានធ្វើជាក់លាក់ ការដកសព្វាវុធពីក្រុមវិវាទខ្មែរ ក៏មិនបានម៉ត់ចត់ ហើយការគ្រប់គ្រងរដ្ឋបាល **ហ៊ុន សែន** ក៏មិនបានជិតដល់ ដូចដែលកិច្ចព្រមព្រៀង បានកំណត់ទេ។ ហេតុនេះ កម្លាំងអាណានិគមនិយមយួន ទាំងកងទ័ព ទាំងពួក«អ្នកជំនាញការ» ទាំងពួកអាណានិគមយួន ជាច្រើនលាននាក់នោះ អាចបន្តនៅកម្ពុជាតទៅទៀត។

គឺដោយសារ កង្វះខាតធំៗខាងលើនៃ អ.ស.ប. នោះហើយ ទើបយួនហាណូយ យល់ថា គេមិនចាំបាច់ នឹងលុបបំបាត់ សន្ធិសញ្ញាអាណានិគមនិយមរបស់គេ នៃថ្ងៃទី ១៨ កម្ភៈ ១៩៧៩ ហៅថា «សន្ធិសញ្ញា សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ» ព្រមទាំងកិច្ចព្រមព្រៀងសន្ធឹកសន្ធាប់ក្នុងគ្រប់វិស័យ ដែលយោងចេញ ពីសន្ធិសញ្ញានេះ មានជាអាទិ កិច្ចព្រមព្រៀងនានា ស្ដីអំពីព្រំដែនថ្មី នៃសមុទ្រ និងដីគោក រវាងវៀតណាម និងអាដ្ឋាធរបរិវាររបស់ខ្លួន ហៅថា «សាធារណរដ្ឋប្រជាមានិតកម្ពុជា» នៃក្រុមលោក **ហេង សំរិន** លោក **ហ៊ុន សែន** ដោយបំពានលើកិច្ចព្រមព្រៀងអន្តរជាតិ ទីក្រុងប៉ារីស ស្ដីពីកម្ពុជា ឆ្នាំ១៩៩១ និងទោះជាមានការជំទាស់ជាខ្លាំង ពីព្រះមហាក្សត្រ **នរោត្តម សីហនុ** ជាប្រមុខរដ្ឋ នៃកម្ពុជាក្ដី។ **ហ៊ុន សែន** *បានប្រកែកនឹងព្រះមហាក្សត្រ មិនព្រមលុបបំបាត់ នូវសន្ធិសញ្ញាអំពីទឹកដី ជាមួយយួននោះដែរ ដោយសំអាងយ៉ាងខ្លី លើ «ទំនាក់ទំនងល្អជានិច្ច» រវាងវៀតណាម និងរដ្ឋាភិបាលគាត់*។ កងទ័ពយួន ក៏បានបន្តកាន់កាប់ និងទាញយកភោគទ្រព្យកម្ពុជា នៃខេត្រធំៗ នៅភាគឦសាន (រតនគីរី, មណ្ឌលគីរី, ស្ទឹងត្រែង, ក្រចេះ) ដោយការបង្កើត តំបន់សកម្មភាពរួមគ្នា ហៅថា «ត្រីកោណឥណ្ឌូចិន» រួចហើយកែជា «ត្រីកោណកម្ពុជា លាវ វៀតណាម»។

គឺដោយសារជំនួយ នៃកម្លាំងយួនទាំងនេះហើយ ទើបបក្សប្រជាជនកម្ពុជា នៃលោក ហ៊ុន សែន អាចគ្របសង្កត់ លើភាគីខ្មែរឯទៀតៗ និងបន្តអំណាចផ្ដាច់ការរបស់ខ្លួន នៅកម្ពុជា។ រីឯមហាអំណាចបស្ចិមប្រទេស (អាមេរិក អឺរ៉ុប ជប៉ុន...) ដែលយល់ថា ហ៊ុន សែន នឹងបោះបង់បទនយោបាយបែបកុម្មុយនីស្ត៍ ហើយនិងធ្វើការតាមគន្លងលទ្ធិប្រជាធិបតេយ្យសេរី (ដូចការកំណត់ នៃកិច្ចព្រមព្រៀង ទីក្រុងប៉ារីស) ក៏បានផ្ដល់ជំនួយហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសង្គមកិច្ចជាច្រើន ដើម្បីពង្រឹងគ្រឹះមូលដ្ឋានថ្មី នៃសង្គមខ្មែរ និងជំហររបស់ ហ៊ុន សែន។ គេមិនបានយកចិត្តទុកដាក់ និងការបន្តបំពាន លើបូរណភាពទឹកដីកម្ពុជា និងការបន្តវត្តមានរបស់កម្លាំងយួនគ្រប់គ្រង នៅក្រោយវាំងននខ្មៅ នៃ«កិច្ចសហប្រតិបត្តិការ» ឥតគណនា ជាមួយរដ្ឋបាលនានានៃកម្ពុជានោះទេ។ គេក៏មិនភ្ញាក់ផ្អើល នឹងការបន្តការប្រព្រឹត្តបំពាន លើសិទ្ធិ-សេរីភាពពលរដ្ឋ និងគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ដោយអំណាច ហ៊ុន សែន នោះទេដែរ រហូតដល់ផ្ទុះរដ្ឋប្រហារបង្ហូរឈាម នៅខែកក្កដា ១៩៩៧ និងការក្ដោបក្ដាប់អំណាចទាំងស្រុង សង្កត់លើស្ថាប័នជាតិទាំងអស់ ដោយ«មនុស្សខ្លាំង» ហ៊ុន សែន ជាបន្ទាប់មក។

ចាប់ពីពេលនោះមក ហ៊ុន សែន បានបង្ហាញបន្តិចម្តងៗ ថាគាត់លែងទទួលស្គាល់ អត្ថិភាព, ឧត្តមភាព និង អានុភាព នៃកិច្ចព្រមព្រៀងអន្តរជាតិ ទីក្រុងប៉ារីស ឆ្នាំ១៩៩១ មកលើច្បាប់ និងលើនយោបាយរបស់កម្ពុជា ដោយគាត់នៅតែរក្សា និងប្រតិបត្តិយ៉ាងហ្មត់ចត់បំផុត នូវកិច្ចព្រមព្រៀងនានា ជាមួយយៀកណាម ពីឆ្នាំ ១៩៧៩ មកនោះ។ ច្បាប់រដ្ឋធម្មនុញ្ញ ត្រូវបាន ហ៊ុន សែន បង្រួញមកនៅពាក្យមួយម៉ាត់ថា «អធិបតេយ្យ» របស់កម្ពុជា (គឺអំណាច ដែលមិននៅក្រោមអំណាចនរណាទៀត ក្នុងការដឹកនាំនយោបាយ និងវាសនាប្រទេសជាតិ) ហើយអធិបតេយ្យរបស់កម្ពុជានេះ ក៏ត្រូវបាន ហ៊ុន សែន បង្វែងន័យមកប្រើជាអធិបតេយ្យរបស់រដ្ឋាភិបាលគាត់ ដែលនៅក្នុងរដ្ឋធម្មនុញ្ញ វាជាអធិបតេយ្យរបស់ប្រជាពលរដ្ឋខ្មែរ (ត្បិតថា «អំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ»!) ហើយដែលត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស លើគ្រប់ចំណុចផង។

អាស្រ័យហេតុទាំងនេះ ទើប ហ៊ុន សែន តាំងពីឆ្នាំ២០១៧ មក បានបង្កើតច្បាប់សន្ធឹកសន្ធាប់ បំផ្លាញសិទ្ធិសេរីភាពធម្មនុញ្ញ របស់ពលរដ្ឋ របស់អ្នកតំណាងរាស្ត្រ និងគោលការណ៍ធម្មនុញ្ញ នៃលទ្ធិប្រជាធិបតេយ្យ។ កងប៉ូលីស កងទ័ព និងតុលាការរបស់គាត់ ក៏ចេញបង្ក្រាបនៅគ្រប់ទីសទី រាល់ការទិតៀន ជំទាស់ និងការតវ៉ារបស់ពលរដ្ឋ និងរបស់បក្សប្រកួត ដោយគេចោទថា វាជាអំពើ«ញុះញង់» ជាការបង្ក «អសន្តិសុខសង្គម» ឬជាអំពើ«ក្បត់ជាតិ» ក្នុងបំណងរំលំរដ្ឋាភិបាល«ស្របច្បាប់»។ នៅក្នុងទំនាក់ទំនងអន្តរជាតិវិញ ការរិះគន់ និងការថ្កោលទោសរបស់ អ.ស.ប. និងរបស់អំណាចបស្ចិមប្រទេស ចំពោះការ រំលោភសិទ្ធិមនុស្ស ឬការបំផ្លាញលទ្ធិប្រជាធិបតេយ្យ ដោយរដ្ឋាភិបាល ហ៊ុន សែន ក៏ត្រូវបានរដ្ឋាភិបាលនេះ បរិហារបញ្ច្រាស់វិញថា វាជាការជ្រៀតជ្រែកក្នុងរឿងផ្ទៃក្នុង នៃកម្ពុជា ឬជាអំពើប៉ះពាល់អធិបតេយ្យរបស់កម្ពុជា។ ការពិត ការចោទប្រកាន់ និងការដាក់ទណ្ឌកម្មសេដ្ឋកិច្ច របស់ អ.ស.ប.ក្តី របស់អឺរ៉ុបក្តី របស់អាមេរិកក្តី តែងតែសំអាងលើការមិនគោរព ដោយរដ្ឋាភិបាល ហ៊ុន សែន ចំពោះបទបញ្ញត្តិនៃកិច្ច ព្រមព្រៀង ទីក្រុងប៉ារីស ឆ្នាំ១៩៩១ នោះ។ ការធ្វើទណ្ឌកម្មផ្សេងៗទៀតរបស់គេ នឹងកើតមានជាប្រាកដដែរ នៅពេលគេឃើញថា ដើម្បីរក្សាអំណាចខ្លួន ហ៊ុន សែន បានលក់អព្យាក្រឹតភាពនៃកម្ពុជា ដែលកិច្ចព្រមព្រៀងទីក្រុងប៉ារីស បានកំណត់ច្បាស់លាស់ ដើម្បីសន្តិភាព និងស្ថិរភាព នៃតំបន់នេះ។

ហ៊ុន សែន បានប្រកាសថ្មីៗនេះថា មិនឲ្យប្រវត្តិសាស្ត្រចាស់ វិលមកឃាយីប្រទេសកម្ពុជា វិញទេ។ ប៉ុន្តែ ហ៊ុន សែន បានភ្លេចថា គឺការមិនគោរពសិទ្ធិមនុស្ស ការបំបាត់លទ្ធិប្រជាធិបតេយ្យ និងការបោះបង់ចោលអព្យាក្រឹត្យនៃកម្ពុជានោះហើយ ដែលបានបើកទ្វារ បើកដៃ ឲ្យសង្គ្រាម និងមហន្តរាយឥតគណនា ចូលមកកំទេចកម្ពុជា។ ហេតុការណ៍នានា ដែលយើងបានឃើញគឺ ហ៊ុន សែន ដែលស្រវឹងនឹងអំណាចគ្មានព្រំដែន បានប្រមាថយ៉ាងធ្ងន់ធ្ងរ ដល់កិច្ចព្រមព្រៀងអន្តរជាតិទីក្រុងប៉ារីស ឆ្នាំ១៩៩១ ហើយបាននិងកំពុងតែរុញកម្ពុជាឲ្យធ្លាក់ទៅក្នុងសង្គ្រាម និងមហន្តរាយដល់ជីវិតនោះ ម្តងទៀត។

ទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ២០២០។


**ឱ កាវ៉េត**

ជ.គណកម្មាធិការ ព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង និងក្នុងពិភពលោក